ក្រសួងមុខងារសាធារណៈ

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

# វគ្គបណ្តុះបណ្តាលមន្ត្រីក្របខណ្ឌថ្មី

# រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នរដ្ឋ


បទបង្ហាញដោយ៖ ឯ.ឧ ឆាយ ឆត្រារុង

អនុប្រធានអចិន្ត្រៃយ៍នៃលេខាធិការដ្ឋាន គ.ក.រ


សាលាភូមិន្ទរដ្ឋបាល ថ្ងៃទី២-៥ ខែវិច្ឆិកា ឆ្នាំ២០១៥







# មាតិកា

១. ប្រព័ន្ធច្បាប់ក្នុងពិភពលោក
២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
៣. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា

# ១. ប្រព័ន្ធច្បាប់ក្នុងពិភពលោក

- ប្រព័ន្ធច្បាប់ រ៉ូម៉ាំង-អាឡឺម៉ង់ ឬ ប្រព័ន្ធច្បាប់ (CIVIL LAW)
- ប្រព័ន្ធច្បាប់ (COMMON LAW)
- ប្រព័ន្ធច្បាប់កុម្មុនីយស្ត
- ប្រព័ន្ធច្បាប់សាសនា

# ១. ប្រព័ន្ធច្បាប់ក្នុងពិភពលោក (ត)

## ១.១ ប្រព័ន្ធច្បាប់រ៉ូមាំង-អាឡឺម៉ង់ ឬប្រព័ន្ធច្បាប់(CIVIL LAW)

- មានដើមកំណើតនៅអឺរ៉ុបកណ្តាល
- ផ្សព្វផ្សាយចេញពីទ្វីបអឺរ៉ុបតាមរយៈការធ្វើអាណានិគម
- មានប្រទេស បារាំង ប្រទេសអឺរ៉ុបកណ្តាលមួយចំនួន ប្រទេសអាមេរិកឡាទីន និងប្រទេសកម្ពុជា ក៏បានប្រកាន់យកមកអនុវត្តផងដែរ





# ១. ប្រព័ន្ធច្បាប់ក្នុងពិភពលោក (ត)

## ១.១ ប្រព័ន្ធច្បាប់រ៉ូម៉ាំង-អាល្លឺម៉ង់ ឬប្រព័ន្ធច្បាប់(CIVIL LAW)

- ប្រទេសក្រោមអាណានិគម អេស្បាញ ព័រទុយហ្កាល បារាំង ហូឡង់ បណ្ដាប្រទេសអាហ្វ្រិកស្បែកខ្មៅ និងប្រទេស ម៉ាដាហ្គាស្កា ឬបណ្ដាប្រទេសអាស៊ី ដូចជា ឥណ្ឌូនេស៊ី ដែលធ្លាប់ស្ថិតនៅក្រោមអាណា និគមហូឡង់ សុទ្ធតែប្រកាន់យកប្រព័ន្ធ Civil Law






# ១. ប្រព័ន្ធច្បាប់ក្នុងពិភពលោក (ត)

## ១.១ ប្រព័ន្ធច្បាប់រ៉ូមាំង-អាឡឺម៉ង់ ឬប្រព័ន្ធច្បាប់(CIVIL LAW)

- លក្ខណៈពិសេស គឺងាយនឹងជះឥទ្ធិពលទៅលើច្បាប់នានា តាមរយៈ វិធានសរសេរដែលមានលក្ខណៈច្បាស់លាស់ និងមាននីតិវិធីចងក្រងច្បាប់ជាក្រម (Code)
- ការចងក្រមជាក្រម ត្រូវបានធ្វើទៅតាមវិស័យ ដូចជា៖ ក្រមការងារ ក្រម រដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមពាណិជ្ជកម្ម...






# ១. ប្រព័ន្ធច្បាប់ក្នុងពិភពលោក (ត)

## ១.២ ប្រព័ន្ធច្បាប់ COMMON LAW

- ជាប្រព័ន្ធដែលមានលក្ខណៈដោយឡែក
- មានប្រភពនៅចក្រភពអង់គ្លេសកើតចេញពីសកម្មភាពនៃសាលាយុត្តិធម៌
- ប្រព័ន្ធច្បាប់Common Law មានប្រទេសអង់គ្លេស អៀកឡង់ដ៍ សហរដ្ឋអាមេរិក និងបណ្តាលប្រទេសនៃសហគមន៍Commonwealth ដែលមានសមាជិកប្រមាណ៥៣ប្រទេស








# ១. ប្រព័ន្ធច្បាប់ក្នុងពិភពលោក (ត)

## ១.២ ប្រព័ន្ធច្បាប់ COMMON LAW

- យកមហាក្សត្រីយានី Elizabeth II របស់អង់គ្លេសធ្វើជាប្រមុខ រដ្ឋរបស់ខ្លួន ឬ អាចនិយាយម៉្យាងទៀតថា ស្ថិតក្រោមឥទ្ធិពលនៃប្រទេសអង់គ្លេស
- ប្រទេស Commonweath ដែលបានបង្កើតឡើង គឺឈរលើគោលការណ៍ សមភាពរវាង រដ្ឋអធិបតេយ្យ និងរដ្ឋអធិបតេយ្យ





# ១. ប្រព័ន្ធច្បាប់ក្នុងពិភពលោក (ត)

## ១.៣ ប្រព័ន្ធច្បាប់កុំម្មុយនីស

- ប្រទេសដែលអនុវត្តតាមបែបមនោគមន៍វិជ្ជា ម៉ាក្ស (Max) និងលេនីន (Lenine) ដូចជា អតីតសហភាពសូវៀត ចិនជាដើម
- លេនីន និយម ប្រាថ្នាចង់លុបចោលច្បាប់ លុបចោលរដ្ឋ ដោយបង្កើតពិភពលោកថ្មីមួយនៅក្នុង ដំណាក់កាលចុងក្រោយរបស់ពួកគេ ប៉ុន្តែ គំនិតទាំងអស់ត្រូវទទួលបរាជ័យពេល ដែលសង្គ្រាមត្រជាក់បានបញ្ចប់នៅឆ្នាំ១៩៩១









# ១. ប្រព័ន្ធច្បាប់ក្នុងពិភពលោក (ត)

## ១.៤ ច្បាប់សាសនា

ប្រទេសដែលអនុវត្តតាមបែបច្បាប់សាសនា មានដូចជា៖

- Afghanistan
- Bangladesh
- The Gambia
- Iran
- Libya
- Mauritania
- Morocco
- Oman
- Saudi Arabia
- Sudan
- Yemen

# ២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបាន៖

- អនុម័តដោយសភាធម្មនុញ្ញ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣
- ប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ១៩៩៣

នៅក្នុងរដ្ឋធម្មនុញ្ញ បែកចេញជា១៦ជំពូក ក្នុងនោះរួមមាន៖

- ជំពូកទី១៖ ពាក់ព័ន្ធទៅនឹងអធិបតេយ្យភាព
- ជំពូកទី២៖ អំពីព្រះមហាក្សត្រ
- ជំពូកទី៣៖ អំពីសិទ្ធ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ
- ជំពូកទី៤៖ អំពីរបបនយោបាយ
- ជំពូកទី៥៖ អំពីសេដ្ឋកិច្ច
- ជំពូកទី៦៖ អំពីអប់រំ វប្បធម៌ និងសង្គមកិច្ច
- ជំពូកទី៧៖ អំពីរដ្ឋសភា

# ២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា(ត)

- ជំពូកទី៨ថ្មី៖ អំពីព្រឹទ្ធសភា
- ជំពូកទី៩ថ្មី៖ អំពីសមាជរដ្ឋសភា និងព្រឹទ្ធសភា
- ជំពូកទី១០ថ្មី៖ អំពីរាជរដ្ឋាភិបាល
- ជំពូកទី១១ថ្មី៖ អំពីអំណាចតុលាការ
- ជំពូកទី១២ថ្មី៖ អំពីក្រុមប្រឹក្សាធម្មនុញ្ញ
- ជំពូកទី១៣ថ្មី៖ អំពីការគ្រប់គ្រងរដ្ឋបាល
- ជំពូកទី១៤ថ្មី៖ អំពីសមាជជាតិ
- ជំពូកទី១៥ថ្មី៖ អំពីអានុភាព ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ
- ជំពូកទី១៦ថ្មី៖ អន្តរប្បញ្ញត្តិ។

# ២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា(ត)

- នៅក្នុងមាត្រា១៥០ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា "រដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា" ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏បានធ្វើវិសោធនកម្មជាច្រើនលើកមានដូចជា៖
  - ការកែប្រែលើកទី១៖ តាមច្បាប់ស្តីពីការកែប្រែមាត្រា២៨ នៃរដ្ឋធម្មនុញ្ញ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៤

# ២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ត)

- <u>ការកែប្រែលើកទី២៖</u> តាមច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១១, ១២, ១៣, ១៨, ២២, ២៤, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤នៃរដ្ឋធម្មនុញ្ញ ដែលប្រកាសឲ្យប្រើដោយព្រះរាជ ក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩

- <u>ការកែប្រែលើកទី៣៖</u> តាមច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៩ និងមាត្រា ២៩នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែល ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៧០១/១១ ចុះថ្ងៃ ទី២៨ ខែកក្កដា ឆ្នាំ២០០១

- <u>ការកែប្រែលើកទី៤៖</u> តាមច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ៨៨ និង មាត្រា ១១១ថ្មី នៃរដ្ឋធម្មនុញ្ញដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/ ០៦០៥/០១៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥

# ២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា(ត)

- <u>ការកែប្រែលើកទី៥៖</u> តាមច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ២៨ និងមាត្រា ៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៦ថ្មី មាត្រា១១១ ថ្មី(មួយ) មាត្រា១១៨ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៣០៦ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៦

- <u>ការកែប្រែលើកទី៦៖</u> តាមច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៤៥ថ្មី និងមាត្រា១៤៦ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខនស/រកម/០២០៨/០០៨ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨

# ២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ត)

- ព្រះរាជាណាចក្រកម្ពុជា ប្រកាន់របបប្រជាធិបតេយ្យរាជានិយម សេរីពហុបក្ស អាស្រ័យរដ្ឋធម្មនុញ្ញ ដោយផ្តោតជាសំខាន់លើអំណាច៣ (អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ អំណាចតុលាការ)

  ១. អំណាចនីតិបញ្ញត្តិ ឋិតនៅក្រោមការអនុវត្តរបស់រដ្ឋសភា និងព្រឹទ្ធសភា

  - មានតួនាទីពិនិត្យ និងអនុម័តច្បាប់ និងតាមដានការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល
  - រដ្ឋសភា មានសិទ្ធកោះហៅនាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល មកឆ្លើយបំភ្លឺពាក់ព័ន្ធទៅនឹងការអនុវត្ត

# ២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា(ត)

២. អំណាចនីតិប្រតិបត្តិ ឋិតនៅក្រោមការអនុវត្តរបស់រាជរដ្ឋាភិបាល

- ជាអំណាចអនុវត្តច្បាប់
- មាននាយករដ្ឋមន្ត្រី១រូបជាប្រមុខរាជរដ្ឋាភិបាល
- សមាជិករាជរដ្ឋាភិបាល រួមមាន ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និងមានការឯកភាពពីសភា

៣. អំណាចតុលាការ ឋិតនៅក្រោមការអនុវត្តរបស់អង្គចៅក្រម

- តែងតាំងដោយព្រះមហាក្សត្រ
- ផ្អែកតាមច្បាប់ និងរដ្ឋធម្មនុញ្ញ ដើម្បីកាត់សេចក្តី

# ៣. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ

## ៣.១. រដ្ឋបាលថ្នាក់ជាតិ

- ព្រះមហាក្សត្រ ជាព្រះប្រមុខរដ្ឋមួយជីវិត
- ព្រះមហាក្សត្រ ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ
- ព្រះមហាក្សត្រ ព្រះអង្គទ្រង់មានព្រះរាជកិច្ចពីរយ៉ាងគឺ៖
    - ព្រះរាជកិច្ច ជាអធិបតី






    - ព្រះរាជកិច្ច ជារដ្ឋបាល (ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាពបានពិនិត្យចប់សព្វគ្រប់រួច និងឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តី ស្នើសុំពីគណៈរដ្ឋមន្ត្រី)

# ៣. រចនាសម្ព័ន្ធគ្រប់គ្រង់រដ្ឋ

- នាយករដ្ឋមន្ត្រី
- ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការប្រធានស្ថាប័ន
- លំដាប់ថ្នាក់រាជរដ្ឋាភិបាល
    - គណៈរដ្ឋមន្ត្រី
    - គណៈកម្មាធិការអន្តរក្រសួង
    - អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

# ៣. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ

- លំដាប់ថ្នាក់ក្រសួង ស្ថាប័ន និងរដ្ឋលេខាធិការដ្ឋាន (៣០ក្រសួងស្ថាប័ន)
  - ក្រុមខុទ្ទកាល័យ
  - ក្រុមរដ្ឋបាលកណ្ដាល (អគ្គនាយកដ្ឋាន នាយកដ្ឋាន ការិយាល័យ ជាដើម)
  - ក្រុមអធិការកិច្ច
  - ក្រុមទីប្រឹក្សា
  - ក្រុមសវនកម្មផ្ទៃក្នុង
  - អង្គភាពលទ្ធកម្ម

# ៣. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ

## ៣.២. រដ្ឋបាលថ្នាក់ក្រោមជាតិ



# ៣. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមមាន គោលបំណងកំណត់ការ គ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក តាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឲ្យ មានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

- គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល គឺផ្ទេរការទទួលខុសត្រូវ និងធនធានដល់ក្រុមប្រឹក្សាដែលជាប់ឆ្នោតនៅ ថ្នាក់ក្រោមជាតិ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានទិសដៅដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងលើកកម្ពស់ការអភិវឌ្ឍនៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

# ៣. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ

- ក្រុមប្រឹក្សា
- គណៈអភិបាល និងអភិបាល
- គណៈកម្មាធិការរបស់ក្រុមប្រឹក្សា
- បុគ្គលិករបស់ក្រុមប្រឹក្សា
- ទំនាក់ទំនងរវាងរដ្ឋាភិបាលជាមួយក្រុមប្រឹក្សា
- ការផ្ទេរមុខងារឱ្យក្រុមប្រឹក្សា
- អំពីឃុំ សង្កាត់

សូមអរគុណ